សុន្ទរកថារបស់**លោក តាខាម៉ូរ៉ា ហ៊ីរ៉ូស៊ី** ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន

១៣ មិនា ២០១២

**សូមគោរព លោក ម៉ុក ម៉ៃ ប្រធានគណៈកម្មាធិការតស៊ូមតិនៃសមាគមអង្គការមិនមែនរដ្ឋាភិបាល!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំា នសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយ គណៈកម្មាធិការតស៊ូមតិនៃសមាគម-អង្គការមិនមែនរដ្ឋាភិបាលសម្រាប់គម្រោងបោះពុម្ពឯកសារពត៌មានស្តីអំពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១២។

បន្ទាប់ពីការចាប់កំណើតឡើងវិញជាព្រះរាជាណាចក្រទី២ក្នុងឆ្នាំ១៩៩៣ កម្ពុជាបានធ្វើការអភិវឌ្ឍឈានទៅមុខជាលំដាប់ និងទទួលបានភាពរីកចម្រើនគួរឲ្យកត់សម្គាល់លើគ្រប់វិស័យជាប្រទេសប្រជាធិបតេយ្យលេចធ្លោមួយតាមរយៈការបោះឆ្នោតជាច្រើនលើក។ ប្រជាជនកម្ពុជាទាំងអស់ប្រហែលជាបានដឹងហើយថាការបោះឆ្នោតគឺជាឧបករណ៍ដ៏មានសារៈសំខាន់បំផុតមួយនិងមានអត្ថន័យជាអាយុជីវិតដើម្បីបញ្ជាក់ពីលទ្ធិប្រជាធិបតេយ្យ និងឆ្លុះបញ្ចាំងពីសំឡេងរបស់ប្រជាពលរដ្ឋសាមញ្ញនៅក្នុងគោលនយោបាយជាតិ និងមូលដ្ឋាន។ វាមានសារៈសំខាន់ណាស់ក្នុងការធានាឲ្យបាននូវសេរីភាព និងតម្លាភាពក្នុងការបោះឆ្នោត ក៏ដូចជាការបង្កើនអត្រាអ្នកចូលរួមបោះឆ្នោតឲ្យបានខ្ពស់ដើម្បីធានាប្រសិទ្ធភាពក្នុងការបោះឆ្នោត។

ដោយសារមូលហេតុនេះ រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយ"គូសាណូណេ"ដែលជាជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិនូវថវិកាចំនួន៩០,៩០០ដុល្លាអាមេរិក សម្រាប់គម្រោងបោះពុម្ពសេចក្តីណែនាំដល់អ្នកបោះឆ្នោតដែលក្នុងនោះមានបញ្ចូលពត៌មានចាំបាច់អំពីការបោះឆ្នោតមានដូចជាសិទ្ធិក្នុងការបោះឆ្នោត នីតិវិធី និងដំណើរការនៃការបោះឆ្នោតជាដើម។ តាមរយៈគម្រោងនេះ អ្នកបោះឆ្នោតជាង៣លាននាក់នៅទូទាំងប្រទេសនឹងទទួលបានពត៌មានដែលមានប្រយោជន៍សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលនឹងប្រព្រឹត្តិទៅនៅខែមិថុនាឆ្នាំនេះ។

ខ្ញុំសង្ឃឹមថាសេចក្តីណែនាំសម្រាប់អ្នកបោះឆ្នោតនេះនឹងមានអត្ថប្រយោជន៍ជួយបង្កើនអត្រាអ្នកចូលរួមបោះឆ្នោតក្នុងការបោះឆ្នោតនាពេលដ៏ខ្លីខាងមុខនេះ ហើយខ្ញុំមានជំនឿជឿជាក់ថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!